**ជំពូកទី ៩**

# ពិការខួរក្បាលដោយមានការលូតលាស់យឺត (Mental Retardation)

## បញ្ញាអន់ វិកលរោគបណ្តាលមកពីក្រពេញសៃរ៉យ និងមូលហេតុផ្សេងទៀត (Down Syndrome, Cetinism, and Other Causes)

បញ្ញាអន់ គឺជាការលូតលាស់យឺតនៃសតិប្រាជ្ញារបស់កុមារ ។ **កុមាររៀនអ្វី១យឺតជាងកុមារដទៃ ក្នុងវ័យដំណាលគ្នា** ។ គេអាចយឺតនៅពេលចាប់ផ្តើមធ្វើចលនាសើច បង្ហាញការចាប់អារម្មណ៍ ការប្រើដៃ អង្គុយ ដើរ និយាយ និងយល់ដឹង ។ ឬគេអាចលូតលាស់ជំនាញមួយចំនួននៃជំនាញទាំងនេះបានលឿន ប៉ុន្តែយឺតផ្នែកផ្សេង១ទៀត ។

បញ្ញាអន់មានលំដាប់ពីស្រាលទៅធ្ងន់ធ្ងរ ។ កុមារដែល*អន់បញ្ញាកំរិតស្រាល* ត្រូវចំណាយពេលច្រើន ដើម្បីរៀនជំនាញមួយចំនួន ។ ប៉ុន្តែដោយមានជំនួយ គេអាចធំធាត់ ថែរក្សាខ្លួនឯង និងចូលរួមដោយសកម្ម ហើយទទួលខុសត្រូវក្នុងសហគមន៍ ។ កុមារដែល *អន់បញ្ញាកំរិតធ្ងន់ធ្ងរ* នៅពេលដែលគេធំឡើង គេអាចនៅតែឋិតក្នុងវ័យទារក ឬកុមារតូច១ ។ គេនឹងតែងតែត្រូវការការថែរក្សាក្នុងមធ្យោបាយមួយចំនួន ។



ដោយមានការជួយ កុមារបញ្ញាអន់មួយចំនួនអាចរៀនអាន និងសរសេរ និងធ្វើអ្វី១ជាច្រើនដូចដែលកុមារដ៏ទៃអាចធ្វើ ។ (រូបភាពរបស់កុមារដែលអន់បញ្ញានៅប្រទេសតណ្ហនេស៊ីថតដោយ ខារូលីន វ៉ាតសន់ ឧបត្ថមដោយមូលនិធិកុមារ គ្រីស្ទាន)

បញ្ញាអន់មិនអាចព្យាបាលបានទេ ។ ប៉ុន្តែ**គ្រប់កុមារអន់បញ្ញាអាចត្រូវបានជួយដើម្បីឱ្យលូតលាស់បានយ៉ាងឆាប់ ។ ការជួយ ឬការពញ្ញោក់ ជាពិសេសកាន់តែចាប់ផ្តើមបានលឿន នោះសមត្ថភាពកាន់តែច្រើន ដែលកុមារទំនងជាទទួលបាន** ។

***សំខាន់*** : នៅក្នុងមេរៀននេះ យើងមើលលើ**មូលហេតុមួយចំនួន នៃការអន់បញ្ញា** និងពិពណនាដោយសង្ខេប ពីទំរង់សាមញ្ញពីរ( បញ្ញាអន់ និងវិកលរោគបណ្តាលមកពីក្រពេញសៃរ៉យ) ប៉ុន្តែ**បញ្ញាអន់គ្រាន់តែជាមូលហេតុមួយ នៃមូលហេតុទាំងអស់ សំរាប់ការលូតលាស់យឺតនៅលើកុមារ** ។ កុមារដែលពិការភ្នែកនឹងយឺតក្នុងការរៀនឈោង និងធ្វើចលនាចុះឡើង *ប្រសិនបើគេពុំ* មានការជួយនិងការលើកទឹកចិត្តបន្ថែម ។ កុមារដែលថ្លង់ និងយឺតក្នុងការរៀនទំនាក់ទំនងប្រសិនណា បើគេមិនត្រូវបានជួយឱ្យរៀន "និយាយ" តាមវិធីផ្សេងជាជាងការនិយាយ ។ កុមារដែលពិការរៀងកាយធ្ងន់ធ្ងរ តែងតែយឺតក្នុងការវិវត្តន៍ ការប្រើទាំងកាយ និងសតិបញ្ញា ។ ព្រោះការ "លូតលាស់យឺត" ជារឿងធម្មតាសំរាប់ជនពិការជាច្រើន យើងនឹងបញ្ចូលការពិភាក្សាពីវា នៅក្នុងមេរៀនដោយឡែកបី ឬបួនមេរៀន ។

ពតិមានស្តីពីការជួយកុមារដែលអន់ខាងបញ្ញា ឬលូតលាស់យឺតនៅក្នុងជំពូកទី ១០ ។ ជំពូកទី ១០ និងទី ១១ ពិភាក្សាពីការអភិវឌ្ឍន៏កុមារតូច និងវិធីជួយ ឬ "ពញ្ញោក់" កុមារឱ្យរៀនជំនាញដំបូង( ដូចជាការប្រើវិញ្ញាណ ការធ្វើចលនា និងការទំនាក់ទំនង) ។ ការពិភាក្សាពី**ការរៀនថែរក្សាខ្លួនឯង**( ការបញ្ចុកអាហារ ការស្លៀកពាក់ ការបន្ទោរបង់ និងការងូតទឹក) និងជំពូកដែលពិភាក្សាពី**ចរិករបស់កុមារ** និងវិធីលើកទឹកចិត្ត ***ចរិក*** ដែលជួយដល់ការសិក្សា ។

គំនិតផ្សេងទៀត ដើម្បីជួយកុមារដែលអន់បញ្ញា នៅក្នុងសកម្មភាពពីកុមារទៅកុមារ ។ តំរូវការ និង បញ្ហារបស់កុមារអន់ខាងបញ្ញានៅពេលដែលគេធំធាត់ខាងភេទត្រូវបានពិភាក្សា ។

តំរូវការចាំបាច់មួយទៀត ដែលយើងពុំបានបញ្ចូលលំអិតនៅក្នុងសៀវភៅនេះ គឺ**ការសិក្សាសំរាប់កុមារអន់បញ្ញា** ។ លទ្ធភាពខ្លះត្រូវបានពិភាក្សាស្តីពីការសិក្សា ។ ប៉ុន្តែតែងតែត្រូវការវិធីសាស្ត្រ និងសំភារៈបង្រៀនផ្នែកសង្គម ។ សៀវភៅដែលប្រណិតគឺ*ការសិក្សាពិសេសសំរាប់កូនសិស្សពិការផ្នែកបញ្ញា*។ ចំពោះឧបករណ៍លេងដែលជួយកុមារឱ្យរៀន ។

## មូលហេតុនៃបញ្ហាអន់

មានមូលហេតុជាច្រើន ដូចជា :

- មូលហេតុតែងតែ**ពុំត្រូវបានដឹង**
- កុមារមួយចំនួនកើតមកមានខួរក្បាលតូច ឬខួរក្បាលមិនលូតលាស់ ឬមិនដំណើរការដូចធម្មតា
- ជួនកាលមាន"**កំហុសឆ្គងនៅក្នុងក្រូម៉ូសូម** " ឬក៏សារធាតុគីមីតូចដែលកំណត់កុមារដូចនឹងអ្វី *(តំណរពូជ)*។ នេះជាអ្វីដែលកើតនៅក្នុងបញ្ហាអន់។
- ជួនកាលម្ដាយមិនបាន**ទទួលអាហារ ឬសារជាតិរ៉ែមួយចំនួនគ្រប់គ្រាន់ អំឡុងពេលមានផ្ទៃពោះ**។(ចូរមើល" ជំងឺវិកលរោគបណ្ដាលមកពីក្រពេញសៃរ៉យ" នៅទំព័រ ១០៦)។
- **ការខូចខួរក្បាល** អាចកើតមានឡើងផងដែរ ពីមុនអំឡុងពេលឬបន្ទាប់ពីប្រសូត។ បន្ថែមពីការអន់បញ្ញា កុមារទាំងនេះអាចខូចខួរក្បាលបញ្ហាចលនា ភាពពិការភ្នែក ភាពថ្លង់ ឬប្រកាច់។ មូលហេតុសាមញ្ញនៃការអន់បញ្ញា មកពីខួរក្បាលខូចត្រូវបាន ពិភាក្សានៅក្នុងជំពូកទី ២ និងរួមមាន :
  - **រោគកញ្ជ្រឹល**អំឡុងពេលមានផ្ទៃពោះ។
  - **រោគរលាកស្រោមខួរ**(ដំបៅខួរក្បាល) ដែលបណ្ដាលមកពីបាក់តេរី រោគរបេង ឬជំងឺគ្រុន់ចាញ់ ភាគច្រើនតែងតែកើតនៅអំឡុងពេលកុមារភាពពីដំបូង។
  - ក្បាលប៉ោងធំ ជារឿយៗជាមួយនឹង គមខ្នងពីកំណើត (ចូរមើលទំព័រទី ៥១)។
  - **គ្រោះថ្នាក់ក្បាល**។
  - មូលហេតុផ្សេងទៀតដែលរួមមាន **ដុះសាច់ខួរក្បាល ការពុល**សំណរ ថ្នាំសំលាប់សត្វល្អិត ឱសថ និងអាហារមួយចំនួន និងទំរង់នៃ**ដំណើរមិនប្រកក្រតីរបស់សរីរាង្គសាច់ដុំ** ឬលែងលូតលាស់។




កុមារដែលមានទំហំក្បាលតូចពេក គឺមានបញ្ហាយឺត ហើយជួនកាលមានបញ្ហាខាងការវិវត្តន៍រាងកាយ។

នៅកន្លែងជាច្រើននៃពិភពលោក មូលហេតុសាមញ្ញបំផុតនៃបញ្ហាអន់ គឺការខូចខួរក្បាល និងការអន់បញ្ញា ប៉ុន្តែនៅតំបន់ភ្នំ វាតែងបណ្ដាលមកពីការ **ខ្វះអ៊ីយ៉ូត** នៅក្នុងអាហារ និងទឹក។

**ជាធម្មតាគ្មានការព្យាបាលសំរាប់ការអន់បញ្ញាទេ** ។ អាស្រ័យដូចនេះ យើងតែងតែមិនត្រូវការដឹងពីមូលហេតុពិតប្រាកដឡើយ។ ជាជំនួស យើងត្រូវការជួយកុមារ ឱ្យវិវត្តបានល្អបំផុតតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែករណីខ្លះឱសថមួយចំនួន ការផ្លាស់ប្ដូរអាហារ ឬការទប់ស្កាត់ពុលបន្ថែម អាចធ្វើឱ្យមានការផ្លាស់ប្ដូរយ៉ាងច្រើន។ ប្រសិនបើកុមារមាន សញ្ញាណវិកល ឬហាក់ដូចជាបាត់បង់សមត្ថភាពបញ្ញាបន្តិចម្ដងៗ ព្យាយាមទទួលដំបូន្មានឱសថពីអ្នកជំនាញ។ **ការទប់ស្កាត់ការអន់បញ្ញា** ត្រូវពិភាក្សារកមូលហេតុផ្សេងៗ។ ជាពិសេស មើលជំងឺខូចខួរក្បាលបញ្ហាចលនា (ទំព័រ ៣៩) បញ្ញាអន់ (ទំព័រ ១០៥) និងជំងឺវិកលរោគ(ទំព័រ ១០៦)។

**ជំងឺផ្លូវចិត្តផ្សេងទៀត**

មនុស្សមួយចំនួនយល់ច្រឡំថា "បញ្ញាអន់ " ជាមួយ "ជំងឺផ្លូវចិត្ត "។ ប៉ុន្តែវាមានលក្ខណៈផ្សេងគ្នា។ មនុស្សដែលមានជំងឺផ្លូវចិត្ត ជួនកាលអាចមានបញ្ញាធម្មតា ឬបញ្ញាខ្ពស់ និងអាចត្រូវរៀនបានខ្ពស់។ ប៉ុន្តែដោយសារតែបទពិសោធន៍នៃជំងឺស្រ្តេស ឬជំងឺមួយចំនួនដែលមានឥទ្ធិពលដល់ខួរក្បាល ចរិកនេះធ្វើឱ្យក្លាយជាចំឡែក។ នៅពេលដែលអ្នកអន់បញ្ញាប្រព្រឹត្តនៅក្នុងវិធីមិនធម្មតា វាក៏ព្រោះតែគេមិនត្រូវបានរៀនតាមវិធីត្រឹមត្រូវដើម្បីប្រព្រឹត្ត គេត្រូវការការបង្រៀន។ មនុស្សដែលមានជំងឺផ្លូវចិត្ត ត្រូវការជំនួយជាពិសេស ប្រហែលជាអ្នកព្យាបាលផ្លូវចិត្ត ឬ "គ្រូពេទ្យចិត្តសាស្ត្រ " (គ្រូពេទ្យខាងផ្លូវចិត្ត)។ **អ្នកដែលមានជំងឺផ្លូវចិត្ត ដូចជាមនុស្សដែលមានជំងឺផ្សេងទៀតដែរ។ ពួកគេតែងតែមិនអាចគ្រប់គ្រងចរិកចំឡែករបស់ខ្លួនបាន។ យើងមិនត្រូវបន្ទោស ឬដាក់ទណ្ឌកម្មពួកគេឡើយ ប៉ុន្តែផ្ដល់ការស្រលាញ់ ការការពារ និងយោគយល់ដល់ពួកគេ ។**

## បញ្ញាអន់

នៅក្នុងតំបន់មួយចំនួន បញ្ញាអន់(mongolism) គឺជាទំរង់សាម័ញ្ញបំផុតនៃភាពយឺតបញ្ញា ឬអន់បញ្ញា។ កុមារទាំងនេះយឺតជាងកុមារផ្សេងទៀត ក្នុងការរៀនប្រើកាយ និងគំនិតរបស់ខ្លួន។ មានសញ្ញា ឬបញ្ហាកាយដែលអាចមើលឃើញមួយចំនួនផងដែរ។ (ការផ្សំនៃសញ្ញាណផ្សេងៗនេះត្រូវបានហៅថា "Syndrome")។ កុមារមិនលូតលាស់តាមធម្មតា នៅក្នុងខ្លួនព្រោះតែមានបញ្ហានៅក្នុង"ក្រូម៉ូសូម" (សារធាតុនៅក្នុងកោសិកានិមួយៗ របស់សពាង្គកាយកំណត់ ពីអ្វីដែលកុមារនឹងត្រូវដូច និងមានរូបរាងយ៉ាងដូចម្ដេច)។

ទាំងនេះជា **សញ្ញាណនៃការអន់ចុះ** (ប៉ុន្តែ *មិនមែនគ្រប់* ក្មេងទាំងអស់មានសញ្ញាណដូចគ្នា *ទាំងអស់* នោះទេ):

- នៅពេលប្រសូតទារកហាក់ដូចជា ទន់អាឡឹក អាឡាក់ និងខ្សោយ។
- ទារកមិនសូវយំច្រើន
- ទារកយឺតជាងទារកផ្សេងៗទៀតក្នុងអាយុដូចគ្នា ដើម្បីក្រឡាប់ កាន់ក្ដាប់វត្ថុ ក្រោកអង្គុយ និយាយ និងដើរ។
- នៅពេលភ្លាមៗដៃធ្លាក់ចុះ ទារកមិនមានប្រតិកម្ម ដោយលាដៃដូចដែលកុមារធម្មតាមានទេ។





- ភ្នែកដៀងឡើងលើ ជួនកាលស្រលៀង ឬមើលមិនសូវឃើញ
- ត្រចៀកទាប
- មាត់តូចចំហរផ្នែកខាងលើមាត់ ខ្ពស់ និងចង្អៀត អណ្ដាតលៀន ចេញ

- ស្បែកបត់គ្របខាងក្នុងនៃកាច់ជ្រុងគ្របកភ្នែក
- គ្របកភ្នែកអាចហើមប៉ោង និងក្រហម
- ប្រស្រីភ្នែកមានរង្វង់សតូច ដូចគ្រប់ខ្សាច់។ បញ្ហាទាំងនេះ តែងតែបាត់ទៅវិញនៅអាយុ ១២ខែ។





- ដៃខ្លី ធំ មានម្រាមខ្លីៗ។ កូនដៃ អាចរួញ ឬបត់បានតែមួយថ្នត់
- មានខ្សែជ្រៅកាត់បាតដៃ(ជួនកាលក៏កើតមានចំពោះកុមារធម្មតាដែរ)

- ក្បាលខ្លីតូចនិងសំប៉ែតធំនៅខ្នង
- ជួនកាលភ្លាត់ត្រគៀក



- មុខសំប៉ែត
- ច្រមុះតូចរាងសំប៉ែតនៅសងខាងច្រមុះ



- កខ្លី
- ស្មាមូល
- ដៃជើងខ្លី
- អង្គុញអិលមកម្ខាង
- " ប្រអប់ជើងតូច" សំប៉ែត
- ម្រាមមេជើងឆ្ងាយពីម្រាមផ្សេង

### សញ្ញាណដែលអាចកើតមានផ្សេងទៀតៈ

- គន្លាក់កែងដៃ ត្រគៀក និងកែងជើង អាចរលុង និងបត់បែនត្រគាក
- កុមារមួយក្នុងចំណោមកុមារ ៣នាក់មានបញ្ហាបេះដូង
- អាចកើតជំងឺ ឈាមសស៊ីឈាមក្រហម (មហារីកឈាម)
- ពិនិត្យមើលកុមារធំពីដែលមានបញ្ហាក្នុងការស្ដាប់ និងមើល
- មួយក្នុង ១០ ខូចទ្រង់ទ្រាយឆ្អឹងក ដែលអាចភ្លេច និងមានជំងឺសសៃប្រសាទ នៅក្នុងឆ្អឹងខ្នង។ ករណីនេះអាចបណ្ដាលឱ្យកើនឡើង ដំណើរកំរើកលែងរួចភ្លាមៗ ឬយឺតៗ ឬស្លាប់ភ្លាម។

## ការថែរក្សាកុមារបញ្ញាអន់ និងទំរង់ផ្សេងនៃបញ្ញាអន់

បញ្ហាអន់ចំពោះកុមារដែលមានបញ្ហាអន់ អាចមានអាការៈស្រាល មធ្យម ឬខ្លាំង។ កុមារខ្លះមិនអាចរៀននិយាយបាន។ កុមារផ្សេងទៀតនិយាយបាន(និងតែងតែចូលចិត្តនិយាយ)។ កុមារជាច្រើនអាចរៀនអាន និងសរសេរ។ កុមារាកុមារីទាំងនេះរាក់ទាក់ណាស់ និងស្រលាញ់រាប់អាន ហើយប្រព្រឹត្តល្អជាមួយអ្នកដទៃដែលធ្វើល្អនឹងគេ។ បើទោះជាកុមារទាំងនេះមានបញ្ហាអន់ខ្លាំងក៏ដោយ ដោយមានការជួយ និងបង្រៀនល្អ តែងរៀនថែរក្សាតំរូវការមូលដ្ឋានរបស់ពួកគេ និងជួយកិច្ចការធម្មតា។ ពួកគេអាចរស់នៅត្រឹមត្រូវបានតាមធម្មតា ជាមួយក្រុមគ្រួសារ និងសហគមន៍របស់គេ។

ជាពិសេសនៅតាមជនបទ ពួកគេអាចរៀនធ្វើកិច្ចការសំខាន់ៗបានជាច្រើន។ ជួនកាលគេធ្វើកិច្ចការដដែលបានល្អ ឬប្រសើរជាងអ្នកដទៃធ្វើ ទៅទៀត។



នៅក្នុងភូមិមួយ កុមារាដែលមានបញ្ហាអន់ម្នាក់ធ្វើកិច្ចការដងទឹកពីស្ទឹង កិច្ចការមានភាពរីករាយ និងមានមោទនៈនឹងធ្វើកិច្ចការនោះ។

ប៉ុន្តែការលូតលាស់កាយ និងបញ្ហាយឺតជាងធម្មតា។ ដូចនេះឪពុកម្តាយ និងអ្នកដែលថែរក្សាកុមារទាំងនេះត្រូវតែអត់ធ្មត់ជាមួយពួកគេតាំងពីដើមដំបូង ធ្វើអ្វីៗទាំងអស់ដែលពួកគាត់អាចធ្វើបាន ដើម្បីជួយកុមារឱ្យលូតលាស់សមត្ថភាពរាងកាយ និងបញ្ញារបស់គេ។ ដើម្បីជាសវាង ឬដោះស្រាយបញ្ហាចរិក ឪពុកម្តាយត្រូវការភាពមិនប្រែប្រួលក្នុងវិធីដែលពួកគាត់ធ្វើលើកូនរបស់ខ្លួន និងក្នុងអ្វីដែលពួកគាត់រំពឹងពីកូន។ កុមារត្រូវការការសរសើរ និងការលើកទឹកចិត្តជាច្រើនចំពោះអ្វីដែលគេធ្វើបានល្អ។

កុមារមួយចំនួនដែលមានបញ្ហាអន់អាចទៅសាលា ប៉ុន្តែពួកគេត្រូវការជំនួយបន្ថែម។ ជាការចាំបាច់ ដែលគ្រូយល់ពីបញ្ហារបស់ពួកគេ និងជួយធ្វើឱ្យកុមារដទៃ ប្រព្រឹត្តមកលើកុមារបញ្ហាអន់ដោយគោរព។ ប្រសិនបើកុមារមិនត្រូវបានផ្តល់ការយោគយល់ និងជំនួយបន្ថែមនៅក្នុងសាលាទេ នៅតំបន់ជនបទអាចជួនកាលប្រសើរជាងសំរាប់កុមារ ដែលមានបញ្ហាអន់ ដើម្បីរៀនសូត្រនៅផ្ទះតាមរយៈការជួយគ្រួសារនៅជុំវិញផ្ទះ និងនៅទីវាល។

មានកង្វល់ធំ ៣ នៅក្នុងការថែរក្សាកុមារ ដែលមានបញ្ហាអន់ :

១. ជួយកុមារឱ្យលូតលាស់សមត្ថភាពបញ្ញា និងកាយរបស់គេ

២. ការពារកុមារកុំឱ្យឆ្លងជំងឺ

៣. ការពារ ឬកែលំអការខូចទ្រង់ទ្រាយ

ទាំងនេះយើងនឹងពិភាក្សាពីកង្វង់ចុងក្រោយ ២។ កង្វល់ទី ១ យើងនឹងពិភាក្សានៅមេរៀនបន្ទាប់។



កុមារាដែលមានបញ្ហាអន់ម្នាក់រៀនដកបង្គោលពីក្តារបង្គោល។ ក្រោយមកនាងរៀនដាក់បង្គោលនោះវិញ។ ថតចេញពី *ទារក ដែលមានបញ្ហាអន់របស់អ្នក* ដោយ ម៉ាកស៊ី ជេហែនសុន

***ចំណាំ :*** ចំពោះកុមារដែលមានបញ្ហាអន់ ឬបញ្ហាយឺត ចូរច្បាស់ថា **ត្រូវអានមេរៀនទាំងអស់ស្តីពីការលូតលាស់របស់កុមារដំបូង និងការសិក្សាពីជំនាញមូលដ្ឋាន។**

## ការការពារនៃការឆ្លងជំងឺ



កុមារដែលមានបញ្ហាអន់ ឈឺច្រើនជាងកុមារដទៃ។ ពួកគេអាចកើតជំងឺផ្តាសាយ ជំងឺរលាកទងសួត និងការងាយឆ្លងជំងឺផ្សេងៗទៀត។ ដូចនេះជាការចាំបាច់ត្រូវថែរក្សាពួកគេ ពីការឆ្លងនេះ។

- **ការបំបៅដោះ**កុមារដ៏វាបណាអាចធ្វើទៅបាន។ ទឹកដោះមាន "អង់ទីករ " ដែលជួយកុមារប្រឆាំង និងការឆ្លងជំងឺ។ ( ប្រសិនបើគេមិនអាចបៅដោះបានល្អចូររីតទឹកដោះរបស់អ្នកបញ្ចុកគេ ដោយប្រើស្លាបព្រា ឬវិធីដែលអាចធ្វើបាន) ។
- ដូចកុមារឯទៀតដែរ នៅអាយុ ៥ ខែ ចូរផ្តើមផ្តល់ចំណីផ្សេងដល់កុមារ ដូចជា ផ្លែឈើ សំណ្តែក ស៊ុត បបរ ប៉ុន្តែបន្តបំបៅដោះគេផងដែរ។ (ក៏ដូចកុមារដទៃ ចូរថ្លឹងគេជារៀងរាល់ខែ នៅឯមណ្ឌលសុខភាព ដើម្បីច្បាស់ថាគេមានការលូតលាស់បានល្អ) ។
- **ការចាក់វ៉ាក់សាំង** អាចការពារកុមារពីជំងឺកុមារ។ កុមារបញ្ហាអន់ដែលកើតជំងឺកញ្ជ្រិល ឬក្អកមាន់អាចកើតជំងឺរលាកទងសួតដោយងាយ។
- **ការយកចិត្តទុកដាក់ផ្នែកឱសថជំបូង** នៅពេលដែលកុមារឈឺបំពង់ក ឈឺត្រចៀក ក្អកខ្លាំង ចូរយកកុមារទៅជួបគ្រូពេទ្យឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## ការទប់ស្កាត់ នៃការខូចទ្រង់ទ្រាយជើង និងបញ្ហាដទៃទៀត

- ពិនិត្យកុមារដែលទើបតែកើតទាំងអស់ រកមើលគ្រគាកភ្លាត់ដែលអាចកើតមាន ដើម្បីកែតំរូវឱ្យបានឆាប់តាមដែលអាចធ្វើទៅកើត។
- ចំពោះកុមារដែលម្រាមមេជើងកន្ទេកពីគេ | កុំប្រើស្បែកជើងរឹង ដែលបត់ម្រាមមេជើងចូលក្នុង ដូចនេះ | ជាការប្រសើរដោយពាក់ស្បែកជើងសំរាប់លេងតឺនីស ឬសែកជើងទន់ៗឬស្បែកជើងសង្រែក






នៅពេលដែលមេជើងធំកន្ទេកចេញខ្លាំង ទីតាំងរបស់វាអាចជួនកាលត្រូវបានកែតំរូវដោយវះកាត់ ដើម្បីឱ្យស្បែកជើងសមល្មមដោយពុំមានបញ្ហា។

- ប្រសិនបើកុមារមានប្រអប់ជើងសំប៉ែត**ខ្លាំង** ទ្រនាប់ជើងពិសេសអាចជួយបាន។
- ប្រសិនបើសញ្ញាណាណាមួយនៃដំណើរកំរើកលែងរួច ឬខ្វះអារម្មណ៍លូតលាស់ ដៃ ជើង ឬសពាង្គកាយ ចូរទទួលដំបូន្មានពីគ្រូពេទ្យខាងរូបរាងកាយ ឬគ្រូពេទ្យសរសៃប្រសាទ។

## ការទប់ស្កាត់ បញ្ហាអន់

កុមារម្នាក់ក្នុងចំណោមកុមារ ៨០០ នាក់ កើតមកមានបញ្ហាអន់ និងវាកើតឡើងយ៉ាងសាមញ្ញបំផុត ចំពោះមាតា ដែលមានវ័យក្រោម ២០ ឆ្នាំ និងលើស ៣៥ ឆ្នាំ ។ ស្ត្រីដែលមានវ័យច្រើនជាង ៤០ ឆ្នាំ ( ឬក៏លើសពី៣៥ ឆ្នាំ ) អាចពិចារណារកុំយកកូនទៀត។ ប្រសិនបើប្តីប្រពន្ធមានកូនបញ្ហាអន់ម្នាក់ ឱកាសនៃការមានកូនដែលមានបញ្ហាអន់ខ្ពស់ជាងធម្មតា ( ប្រហែល ១ ក្នុង ៥០) ។

នៅក្នុងប្រទេសមួយចំនួនការធ្វើតេស្ត (amniocentesis) អាចត្រូវបានធ្វើប្រហែលជារយៈ ៤ ខែ នៃការមានផ្ទៃពោះ ដើម្បីមើលថាតើ កុមារនឹងមានជំងឺបញ្ហាអន់ឬទេ? ។ ប្រសិនបើមាន គ្រួសារអាចពិចារណាពន្លូតចោល ( នៅក្នុងសង្គមជាច្រើន ការពន្លូតកូនត្រូវបានអនុញ្ញាត) ។

## ពិការរោគបណ្ដាលមកពីក្រពេញសៃរ៉យ ឬទីរ៉ូអ៊ីដ

រោគវិកល បណ្ដាលមកពីក្រពេញសៃរ៉យ គឺជាការពន្យឺតទាំងការលូតលាស់នៃពញាណនិងរាងកាយ ដែលកើតមានឡើង នៅពេលខ្លួនរបស់កុមារមិនបានបង្កើត "ទីរ៉ូអ៊ីដ" ឱ្យបានគ្រប់គ្រាន់។ ទីរ៉ូអ៊ីដ ជាសារធាតុមួយឬជា" អ័រម៉ូន" ដែលគ្រប់គ្រងការលូតលាស់របស់កុមារ និងមុខងាររបស់សរីរាង្គកាយ។ បើគ្មានវាអ្វីៗនឹងដំណើរការយឺតទៅៗ។




ទីរ៉ូអ៊ីដ ត្រូវបានផលិតដោយក្រពេញមួយនៅពីមុខក។ ដើម្បីផលិត ទីរ៉ូអ៊ីដ ក្រពេញត្រូវការអ៊ីយ៉ូត។ មនុស្សភាគច្រើនទទួលបាន សារធាតុអ៊ីយ៉ូតគ្រប់គ្រាន់ពីទឹក និងអាហារ។ ប៉ុន្តែនៅក្នុងតំបន់ខ្លះ ជាពិសេសនៅតំបន់ភ្នំ ដី ទឹក និងអាហារមានអ៊ីយ៉ូតតិចតួច។ ក្នុងបំណងដើម្បីទទួលបានអ៊ីយ៉ូតច្រើនក្រពេញ ទីរ៉ូអ៊ីដ ជួនកាលលូតលាស់យ៉ាងធំ ដែលបង្កើតអោយមានការហើមប៉ោង ដែលត្រូវបានគេហៅថាជំងឺពកក។

នៅកន្លែងដែលមានអ៊ីយ៉ូតតិចនឹងមានពលរដ្ឋច្រើនកើតជំងឺពកក វិកលរោគបណ្ដាលមកពីក្រពេញ ទីរ៉ូអ៊ីដ ជារឿងធម្មតា។ នៅក្នុងតំបន់ដូចគ្នាទាំងនេះ កុមារជាច្រើនតែងតែមានការ**លំបាកខាងការស្ដាប់** ឬអ្វីដែល**បង្អង់បញ្ញា**។ ទោះជាគេមិនបានបង្ហាញពីសញ្ញាធម្មតានៃវិកលរោគនេះក៏ដោយ ក៏មូលហេតុប្រហែលជាដូចគ្នា។ ម្ដងម្កាលនៅតំបន់ដែលជំងឺពកកមិនធម្មតា វិកលរោគកើតឡើង ដោយហេតុផលផ្សេង ជាជាងការខ្វះជាតិអ៊ីយ៉ូត។

**សញ្ញាណ** ខាងក្រោម យើងបង្ហាញពីសញ្ញាណធម្មតាខ្លះៗ នៃជំងឺវិកលរោគបណ្ដាលមកពីក្រពេញទីរ៉ូអ៊ីដ និងប្រៀបធៀបសញ្ញាណទាំងនោះជាមួយជំងឺបញ្ញាអន់ ដែលវិកលរោគបណ្ដាលមកពីក្រពេញ ទីរ៉ូអ៊ីដ ផ្សំឡើងតាមវិធីផ្សេង។ វាពិបាកនឹងប្រាប់ថាតើកុមារដែលទើបតែកើតមានវិកលរោគបណ្ដាលមកពីក្រពេញទីរ៉ូអ៊ីដឬអត់។ កុមារតែងតែកើតមកធំ ហើយមិនលូតលាស់តាមធម្មតា។ ទារកអាចពិបាកបំបៅ ឬដកដង្ហើមដោយពិបាក ឬធ្វើសំលេងព្រោះតែអណ្ដាតធំ។ កុមារធ្វើចលនា និងយំតិចតួច។ នៅអាយុ ៣ ទៅ ៦ ខែ ម្ដាយតែងតែបារម្ភ ព្រោះកូនមើលទៅហាក់ដូចជាស្ពឹក ចាប់អារម្មណ៍ពីអ្វីៗតិចតួច ដេកច្រើន និងយឺតក្នុងការលូតលាស់។

| | | |
|---|---|---|
| សញ្ញានៃ**រោគបណ្ដាលមកពីក្រពេញ ទីរ៉ូអ៊ីដ**<br><br>• សីតុណ្ហភាពក្រោមធម្មតា<br>• ស្បែកក្រាស់ ស្ងួត ត្រជាក់<br>• សក់ធ្លាក់លើថ្ងាស<br>• ត្របកភ្នែកប៉ោង<br>• ខ្ទង់ច្រមុះត្រប៉ែតរវាងភ្នែក<br>• មុខ ដៃ ជើង ប៉ោង<br>• ហើមប៉ោងនៅទីនេះ<br>• លូតលាស់យឺត ទាបជាងវ័យកើនឡើង<br>• ទល់លាមកធ្ងន់ធ្ងរ (អាចមិនបន្ទោបង់មួយថ្ងៃ)<br>• ឧស្សាន៍ស្ដាប់មិនលឺ<br>• នៅពេលកុមារធំ ជង្គង់អាចធំ និងមានការឈឺចាប់ | សញ្ញាណដែលឃើញមានចំពោះទាំង **វិកលរោគបណ្ដាលមកពីក្រពេញទីរ៉ូអ៊ីដ និងបញ្ញាអន់**<br>• ការលូតលាស់បញ្ញា និងកាយយឺត<br>• ភ្នែកចែកពីគ្នាយ៉ាងទូលាយ<br>• មុខមូល មើលទៅស្ពឹកៗ<br>• អណ្ដាតលានចេញ និងមាត់ចំហរ<br>• ក និងអវយវៈខ្លី ប្រអប់ដៃខ្លីធំ<br>• ពោះធំ និងអ៊ែន<br>• តែងតែកើតក្លួនលូននៃផ្ចិត<br> | សញ្ញាណ **វិកលរោគបណ្ដាលមកពីក្រពេញទីរ៉ូអ៊ីដ និងបញ្ញាអន់** (ដែលមានសារៈបំផុតក្នុងការប្រាប់វាពីវិកលរោគ)<br>• សក់ចាប់ផ្ដើមខ្ពស់ពីលើថ្ងាស់<br>• ភ្នែកសំលាង ដោយត្របកភ្នែកបត់ពីក្នុងកាច់ជ្រុង<br>ចំពោះសញ្ញាណផ្សេងទៀត ចូមើលទំព័រ ២៧៩<br> |

**អ្វីដែលត្រូវធ្វើ** ការព្យាបាលដំបូងនិងជាបន្តបន្ទាប់ ដោយប្រើ**ឱសថទីរ៉ូអ៊ីដ** ជួយកែលំអការលូតលាស់លក្ខណៈរូបរាង និងជួនកាលអាចកាត់បន្ថយ ឬការពារការអន់បញ្ញា។ សំរាប់លទ្ធផលដែលប្រសើរ ការព្យាបាលគួរតែចាប់ផ្ដើមអំឡុងពេលខែដំបូងនៃជីវិត។ ចំពោះមូលហេតុនេះ **ដរាបណាអ្នកសង្ស័យថាទារកអាច កើតវិកលរោគបណ្ដាលមកពីក្រពេញទីរ៉ូអ៊ីដ ចូរទៅទទួលដំបូន្មានឱសថដែលមានជំនាញ**។

ដើម្បីជួយកុមារឱ្យលូតលាស់ញាណនិងរាង្គកាយ និងរៀនជំនាញមូលដ្ឋាន និងប្រើគំនិតដែលអាចជួយឆ្លើយតប និងតំរូវការរបស់កុមារ។ ដោយមានការព្យាបាលដំបូង និងការសិក្សាណែនាំ កុមារជាច្រើនដែលមានវិកលរោគបណ្ដាលមកពីក្រពេញទីរ៉ូអ៊ីដអាចរៀនថែរក្សាខ្លួនគេ និងធ្វើកិច្ចការធម្មតា ប៉ុន្តែសំខាន់សំរាប់នៅក្នុងសហគមន៍។ សំរាប់គំនិតស្ដីពីការគ្រប់គ្រងការទល់លាមក។

**ការទប់ស្កាត់** នៅក្នុងតំបន់ដែលជំងឺពកកកើតមានជាធម្មតា វិកលរោគបណ្ដាលមកពីក្រពេញទីរ៉ូអ៊ីដ (និងជំងឺថ្លង់) អាចត្រូវបានកាត់បន្ថយយ៉ាងច្រើន ដោយការលើកទឹកចិត្តអ្នករាល់គ្នាអោយប្រើអំបិលដែលមានជាតិអ៊ីយ៉ូត។